ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល

ជាតិ សាសនា ព្រះមហាក្សត្រ

សភាផ្នែករដ្ឋប្បវេណី

*******

សំណុំរឿងរដ្ឋប្បវេណី

លេខ ១៤ប្រ.

ចុះថ្ងៃទី២៩ខែមករាឆ្នាំ១៩៩៩

សាលដីកា

លេខ : ៣០

ចុះថ្ងៃទី២២ខែកុម្ភៈឆ្នាំ២០០០

នាមនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០

ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ឌិត មុន្ទី ប្រធាន

២- លោក ម៉ែន ស៊ុន ចៅក្រម

៣- លោក រៀល មួន ចៅក្រមរបាយការណ៍

៤- លោក ជីវ កេង ចៅក្រម

៥- លោក ស៊ិន ឌឹម ចៅក្រម

ក្រឡាបញ្ជី

លោក ហេ វ៉ាន់ថន

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ១០ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៩៤ ចុះថ្ងៃទី ០១-១២-៩៨ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខ លោក ប៊ូ សារុន ( ជាមេធាវី និងតំណាងឱ្យសាលាខេត្តបាត់ដំបង ) ។

និងចុងបណ្តឹងសាទុក្ខ អ្នកស្រី ឆ វិល័យ អាយុ៤១ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះលេខ ៤៣៧ ក្រុម១៣ ភូមិរតនះ ឃុំរតនះ ស្រុកស្វាយតៅ ខេត្តបាត់ដំបង ( តំណាងឱ្យក្រុមហ៊ុនវិនិយោគទុន អាជីវកម្មផាស៊ី ស្ទឹងត្រី ខេត្តបាត់ដំបង ) ។

មានលោក ជា សេង ជាមេធាវី

តតីយជន : អ្នកស្រី សុខ សុខុន អាយុ ៤៨ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះ

លេខ ១៧២ ក្រុម៤០ ភូមិ២០ឧសភា ឃុំស្វាយពោធិ៍ ស្រុកស្វាយពោធិ៍ ខេត្តបាត់ដំបង ។

<u>កម្មវត្ថុបណ្តឹង</u> : ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចលេខ ១១៦២ ស.រ របស់តុលាការខេត្តបាត់ដំបង ។

បានឃើញបណ្តឹងសាទុក្ខលេខ២២ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៩៩ របស់លោក ប៊ូ សារ៉ុន បានប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលដីកាលេខ១០ ចុះថ្ងៃទី០៤ ខែមករាឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៤ប្រ. ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ១៩៩៩ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ០៥_៧_៩៨ អ្នកស្រី ជា ឆវិល័យ ប្តឹងថា កាលពីថ្ងៃទី២០_០១_៩៧ ក្រុមហ៊ុនរបស់អ្នកស្រី បានចុះកិច្ចសន្យាជាមួយអភិបាលខេត្តបាត់ដំបង ដោយមានការឯកភាពរបស់ក្រសួងសេដ្ឋកិច្ច ស្តីពីការវិនិយោគទន់អជីវកម្មផាសុីស្តង់ត្រីស្រស់ ( ទឹក_គោក ) ខេត្តបាត់ដំបង ។

តាមខ្លឹមសារ នៃកិច្ចសន្យាខាងលើត្រង់ប្រការ២ ចំណុចទី៤ គឺភាគី ( ក ) អភិបាលខេត្តបាត់ដំបងបានអះអាងទប់ស្កាត់មិនអនុញ្ញាតិឱ្យមានបង្កើតស្តង់ត្រីថ្មីបន្ថែមទៀតក្នុងខេត្តបាត់ដំបង ។ មានន័យថា មានតែស្តង់ត្រីរបស់ក្រុមហ៊ុនខ្លួនតែម្នាក់គត់ ដែលមានសិទ្ធិធ្វើអាជីវកម្ម តាមកិច្ចសន្យាក្នុងខេត្តបាត់ដំបង ។ ប៉ុន្តែអភិបាលខេត្តបែរជា អនុញ្ញាតិឱ្យអ្នកស្រីសុខ សុខុន បង្កើតស្តង់ត្រីមួយទៀតដែលមានទីតាំងនៅជិតក្រុមហ៊ុនរបស់ខ្លួន តាមដីកាសំរេចលេខ ១៤៥ស.ស ចុះថ្ងៃទី ១៧_១២_៩៧ ។ ការនេះគឺអភិបាលខេត្តបានបំពានលើកិច្ចសន្យា ដែលបានធ្វើជាមួយក្រុមហ៊ុនរបស់ខ្លួន និង បណ្តាលឱ្យបាត់បង់ផលប្រយោជន៍របស់ក្រុមហ៊ុនខ្លួនយ៉ាងធ្ងន់ធ្ងរ ។

តាមបណ្តឹងចុះថ្ងៃទី ២៩_១០_៩៨ លោក ប៊ូ សារ៉ុន មេធាវីការពារឱ្យសាលាខេត្តបាត់ដំបង បានបញ្ជាក់ថា : ខ្លួនជាមេធាវីការពារឱ្យនីតិបុគ្គលសាលាខេត្តបាត់ដំបង សុំប្តឹងតុលាការខេត្តបាត់ដំបង បង្វែរសមត្ថកិច្ច នៃរឿងក្តីរដ្ឋប្បវេណីលេខ ១៣៧ ចុះថ្ងៃទី ៣០_៧_៩៨ នេះ ឱ្យទៅជាសមត្ថកិច្ចសាច់រឿង វិវាទរដ្ឋបាលដោយផ្អែកតាមគោលការណ៍ នៃ នីតិសាធារណៈ គឺ

១_ បណ្តឹងសុំឱ្យខេត្តគោរពកិច្ចសន្យា រវាងនីតិបុគ្គលសាលាខេត្ត និង រូបវន្តបុគ្គលឯកជន នោះជាវិវាទរដ្ឋបាល ព្រោះនីតិបុគ្គលសាធារណៈមិនអាចមកទទួលខុសត្រូវរដ្ឋប្បវេណី ឬកាតព្វកិច្ចណាមួយជាមួយភាគីរូបវន្តបុគ្គល ឯកជនបានឡើយ ។

ម្យ៉ាងទៀតកិច្ចសន្យានេះ ធ្វើដោយខុសវិន័យពីនីតិវិធីរដ្ឋបាល នៃរបៀបរបបការងារ ។ ជំទាញទៀតផង - ការងារនេះអាចបញ្ជាក់បានដោយអភិបាលខេត្ត និង មន្ត្រីដែលមានសមត្ថកិច្ចរបស់សាលាខេត្តជាបន្ទាល់ ។

២-　ចំពោះការប្តឹងរំលាយ ដីកាសំរេចលេខ១៤៥ ចុះថ្ងៃទី ១៧-១២-៩៧ នោះគឺជាវិវាទរដ្ឋបាលពេញលេញ១០០% មិនអាចបំភ័ន្តថា ជាវិវាទផ្សេងបានទេ ដែលបច្ចុប្បន្ននេះវាស្ថិតនៅក្នុងសមត្ថកិច្ចសាច់រឿងវិវាទរដ្ឋប្បវេណីទៅវិញ ។

៣-　ការប្តឹងសុំឱ្យ សុខ សុខុន រុះរើស្តង់គ្រឿងចេញនោះ ក៏ជាវិវាទ នៃសមត្ថកិច្ចសាច់រឿងរដ្ឋបាលយ៉ាងពេញលេញដែរ ព្រោះថា ភាគីទាំង២ មិនអាចទំនាក់ទំនងរដ្ឋប្បវេណីកាតព្វកិច្ចអ្វីរវាងគ្នាដាច់ខាត ព្រោះថា ស្តង់គ្រឿ អ្នកស្រី សុខ សុខុន កើតឡើងតាមច្បាប់ជាធម្មានុរូប ។

បានឃើញសេចក្តីសំរេចលេខ ១១៦២ ស.រ ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ ១៩៩៨ របស់តុលាការខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

-　បដិសេធចោលនូវពាក្យបណ្តឹងអំពីទម្រង់ច្បាប់ ចុះថ្ងៃទី២៩-១០-១៩៩៨ របស់លោក មេធាវី ប៊ូ សារ៉ុន ដោយខុសនឹងគតិច្បាប់ ។

តាមបញ្ញាតិមាត្រា ៦ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជំរះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨-២-១៩៩៣ និង បញ្ញត្តិមាត្រា ១០៩ នៃរដ្ឋ-ធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ។ បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១០២ ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ១៩៩៨ របស់តុលាការខេត្តបាត់ដំបង បានប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចលេខ ១១៦២ស.រ ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ១៩៩៨ របស់តុលាការខេត្តបាត់ដំបង ទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១០ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ចំពោះមុខមេធាវីការពារដើមចោទ កំបាំងមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-　ទទួលបណ្តឹងឧទ្ធរណ៍លេខ១០២ ចុះថ្ងៃទី ២៩-១០-១៩៩៨ របស់លោកប៊ូ សារ៉ុន មេធាវីការពារក្តី ជូនសាលាខេត្តបាត់ដំបង ទុកជាត្រឹមត្រូវតាមទំរង់ តែត្រូវបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-　ដំកល់សេចក្តីសំរេចលេខ ១១៦២ ស.រ ចុះថ្ងៃទី ២៩-១០-៩៨ របស់តុលាការខេត្តបាត់ដំបង ទុកជាបានការពេញទាំងមូល ។

៣-　បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៩៥១ ចុះថ្ងៃទី០១-១២-១៩៩៨ របស់សាលាឧទ្ធរណ៍ទៅតុលាការខេត្តបាត់ដំបង ដើម្បីជំនុំជំរះ ផល់រឿងអង្គសេចក្តី ។

៤-　រឹបអូសប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយគឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹង ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាត់ហិបប្រាក់ ៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥០០០រៀល និងចំណាយលើអាផ្ទាធរតុលាការ ៥០០០រៀល សរុប១៣.០០០រៀល។

៥- សាលដីកានេះ មានអានុភាពអនុវត្តភ្លាមៗ ទោះមានបណ្តឹងសាទុក្ខក៏ដោយ ។

៦- សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវីការពារដើមចោទ កំបាំងមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ២២ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ១៩៩៩ របស់លោក ប៊ូ សារុន បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ១០ ចុះថ្ងៃទី ០៤ ខែមករា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ :

- បណ្តឹងសាទុក្ខរបស់ចុងចម្លើយស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះ មកពិនិត្យពិចារណា .

- សាលដីកាដូច្នេះណឹ របស់សាលាឧទ្ធរណ៍ បានសំរេចត្រឹមត្រូវតាមគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់តទៅ ។

ក្រឡាបញ្ជីអានសារណការបស់លោក ប៊ូ សារុន

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី ជា នេង នៅពេលជំនុំជំរះថា: រឿងនេះកើតឡើងពីលោកចៅហ្វាយខេត្ត មិនគោរពតាមកិច្ចសន្យា ដោយលោកចៅហ្វាយខេត្តបានចេញសេចក្តីសំរេចឱ្យបង្កើតស្តង់ត្រីមួយកន្លែងហើយ ក្រោយមកទៀតក៏ចេញសេចក្តីសំរេចឱ្យបង្កើតស្តង់ត្រីមួយកន្លែងទៀតដោយមិនគោរពតាមកិច្ចសន្យារបស់ខ្លួន ។

ចំពោះខ្ញុំជាមេធាវីឱ្យ ( ចុងបណ្តឹងសាទុក្ខ ) ពុំមានយោបល់អ្វីទៀតទេ ព្រោះមានលិខិតលេខ ៥២ ចុះថ្ងៃទី ១៧-២-៩៩ របស់តុលាការកំពូលមួយហើយ ។

សូមក្រុមប្រឹក្សាពិនិត្យ និង សំរេច តាមការគួរ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណការបស់លោកមេធាវី ប៊ូ សារុន នឹងសេចក្តីសន្និដ្ឋាន របស់លោកមេធាវី ជា នេង.
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ២២ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៩៩ របស់លោកមេធាវី ប៊ូ សារុន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ទោះបីរឿងនេះ ជារឿងរដ្ឋប្បវេណីក្តី រឿងរដ្ឋបាលក្តីក៏តុលាការមាន សមត្ថកិច្ចជំនុំជំរះដែរ ដូចដែលកំណត់នៃមាត្រា ១២៨ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

- យល់ឃើញថា លោកប៊ូ សារ៉ុន បានធ្វើសារណាការពារក្តីរបស់លោកជូនមកតុលាការ កំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខលោក ប៉ុន្តែចាត់ទុកជាចំពោះមុខលោក ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១០ ចុះថ្ងៃទី ០៤ ខែមករា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែល...សំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវ ទាំងទំរង់និងគតិច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខលោកមេធាវី ជា ផេង កំបាំងមុខលោក

មេធាវី ប៊ូ សារ៉ុន ប៉ុន្តែចាត់ទុកជាចំពោះមុខ .

១- ទទួលបណ្តឹងសាទុក្ខលេខ២២ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៩៩ របស់លោកមេធាវី ប៊ូ សារ៉ុន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ១០ ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ១៩៩៩ របស់ សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលលោកប៊ូ សារ៉ុន បានបង់រួចហើយគឺ:

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

- ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ។

៤- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែកុម្ភៈឆ្នាំ២០០០។